# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

## របាយការណ៍
## កិច្ចប្រជុំអនុក្រុមការងារទី ១

ឆ្នាំពីរពាន់ប្រាំពីរ ខែ កញ្ញា ថ្ងៃទីបី វេលាម៉ោងប្រាំបីកន្លះព្រឹក នៅសាលប្រជុំរបស់អង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ មានរៀបចំកិច្ចប្រជុំរបស់អនុក្រុមការងារទី ១ ដើម្បីពិនិត្យពិភាក្សា និងតាមដាន លើការងាររបស់អនុក្រុមការងារទី ១ ដែលទាក់ទងនិងយុទ្ធសាស្ត្រទី ១ និងទី ៦ នៃកំណែទម្រង់ច្បាប់ និងតុលាការ។

សមាសភាពអ្នកចូលរួមមាន ៖

| | |
|---|---|
| ១. លោក កុយ នាម | UNDP |
| ២. លោក ឃ្លោក ដារ៉ា | PMU |
| ៣. លោក កួយ សៅ | PMU |
| ៤. ជ សៀកវេង | CCJAP |
| ៥. លោក វង្ស តុន | UNHCHR |
| ៦. កែវ សុខគា | UNICEF |
| ៧. ណៃត អង្គារ័ត | MOEYS |
| ៨. ជ្រា ដាលីយ៉ា | CCJAP |
| ៩. សុង វណ្ណស៊ីន | EU |
| ១០. ផាន ពិសីនលក្ខណ៍ | PMU |
| ១១. លោក George Cooper | GTZ |

ជាកិច្ចចាប់ផ្តើម លោក កុយ នាម ជាអ្នកសម្របសម្រួលអនុក្រុម បានជម្រាបជូនអំពីរបៀបវារៈនៃ កិច្ចប្រជុំដែលមាន (១) ការធ្វើបច្ចុប្បន្នភាពបញ្ជីរគម្រោង, (២) សមាជិកភាពរបស់អនុក្រុមទាក់ទងនិង ការងារសិទ្ធិមនុស្ស, (៣) ធ្វើបច្ចុប្បន្នភាពគម្រោងសកម្មភាពសិទ្ធិមនុស្ស,

(៤) ការងារផ្សេងៗ និង (៥) កាលបរិច្ឆេទកិច្ចប្រជុំលើកក្រោយ។ បន្ទាប់មក លោកបានលើកឡើងជាសង្ខេបអំពីលទ្ធផលនៃកិច្ចប្រជុំលើកមុន ដែលផ្តោតជាសំខាន់លើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (ADR) ។

(១) ការធ្វើបច្ចុប្បន្នភាពបញ្ជីគម្រោង

លោក ឃ្លោក ដារ៉ា ៖ យើងបានទទួលរបាយការណ៍ពីក្រសួងមួយចំនួនរួចហើយ ដូចជាក្រសួងអប់រំ ក្រសួងកិច្ចការនារីជាដើម។ ចំណែក Project Profile យើងបានទទួលពី UNDP, CCJAP ប៉ុន្តែនៅស្ថាប័ន មួយចំនួនទៀតកំពុងធ្វើដូចជាក្រសួងពាណិជ្ជកម្ម ក្រសួងមហាផ្ទៃជាដើម ហើយលោកបានស្នើសុំឱ្យស្ថាប័នពាក់ព័ន្ធ ផ្សេងទៀត មេត្តាផ្តល់ Project Profile ឱ្យបានឆាប់តាមតែអាចធ្វើទៅបាន ។ ជាមួយគ្នានេះដែរ លោកបានពន្យល់ត្រួសត្រាយពីគោលបំណង និងរបៀបបំពេញ Project Profile ដល់លោក Cooper ដែលជាសមាជិកថ្មី មកពីអង្គការ GTZ ក្នុងគម្រោងគណៈកម្មការសុរិយោដី ផងដែរ។

(២) សមាជិកភាពរបស់អនុក្រុម ទាក់ទងនិងការងារសិទ្ធិមនុស្ស

លោក កុយ នាម ៖ បានលើកឡើងថា តើសមាជិកភាពដែលទាក់ទងនិងសិទ្ធិមនុស្សពោលគឺ យុទ្ធសាស្រ្តទី ១ គ្រប់គ្រាន់ហើយឬនៅ? លោក ជ សៀកវេង បានលើកឡើងថា ចំពោះសមាជិកភាពនេះ ជាបឋមយើងផ្តោតតែម្ចាស់ជំនួយ ឬដៃគូរអភិវឌ្ឍ និងស្ថាប័នរដ្ឋតែប៉ុណ្ណោះ។

(៣) ធ្វើបច្ចុប្បន្នភាពគម្រោងសកម្មភាពសិទ្ធិមនុស្ស

លោក កុយ នាម បានលើកឡើងចំពោះចំនុចសកម្មភាព ១.៤.៥ ថាតើយើងមានយន្តការអ្វីខ្លះទៀត ដើម្បីជំរុញអោយមានការចូលរួមរបស់សង្គមស៊ីវិលកាន់តែសកម្មឡើង នៅក្នុងការកំណែទម្រង់ច្បាប់និងតុលាការ។ លោក ជ សៀកវេង បានលើកលើងថា ចំពោះចំនុច ១. ៤. ៥ ដែលលើកឡើងពីការចូលរួមរបស់សង្គមស៊ីវិល ក្នុងកំណែទម្រង់ច្បាប់ និងតុលាការនោះ យើងឃើញថា សង្គមស៊ីវិលបានចូលរួមច្រើនហើយ ទៅតាមគម្រោងរបស់គេនីមួយៗនៅតាមសហគមន៍នានាដែលទាក់ទងនិងការកែទម្រង់នេះ។ ប៉ុន្តែយើងនូវមានបញ្ហាខ្លះដូចជាការទំនាក់ទំនង ការសម្របសម្រួល និងការសហការគ្នា ដែលមិនទាន់បានល្អនៅឡើយ។ ដូច្នេះយើងត្រូវការយន្តការបន្ថែមទៀតដើម្បីលើកកំពស់ក្នុងការចូលរួមរបស់សង្គមស៊ីវិលនេះ។

លោក កែវ សុខគា និងលោក កុយ នាម ៖ ត្រង់ចំនុច ១. ៤. ៥ នេះ យើងមិនអាចវាស់វែងបានទេចំពោះការចូលរួមរបស់សង្គមស៊ីវិលនោះ លុះត្រាតែមានយន្តការមួយអោយបានច្បាស់លាស់ដូចជាការប្រជុំអោយបានទៀងទាត់ជាមួយគ្នា ឬការពិគ្រោះយោបល់ជាមួយគ្នាជាពិសេសជាមួយនិងអង្គភាពគ្រប់គ្រងគម្រោងជាដើម។

កញ្ញា ណៃត អង្គារ័ត្ន ៖ បានលើកឡើងនូវចំនុច ១.១.៤ ស្តីពីការបញ្ចូលសិទ្ធិមនុស្ស និងពលរដ្ឋវិទ្យាទៅ ក្នុងកម្មវិធីសាលារៀន និង ១.២.៣ ស្តីពីការបញ្ចូលសិទ្ធិមនុស្សទៅក្នុងកំរិតសាកលវិទ្យាល័យ។ កញ្ញាបានលើកឡើងថា កម្មវិធីបណ្តុះបណ្តាលសិទ្ធមនុស្សនេះ បានបញ្ចូលទៅក្នុងសាកលវិទ្យាល័យមួយចំនួនរួចហើយ ប៉ុន្តែសាលា ខ្លះមិនទាន់បានបញ្ចូលទេពីព្រោះខ្វះគ្រូ។ យើងបញ្ចូលបានតែសាលារដ្ឋទេ ចំពោះឯកជនមិនទាន់បានបញ្ចូលនៅឡើយទេ។ ចំណែកនៅកំរិតបឋម និងមធ្យមយើងបានបញ្ចូលរួចរាល់អស់ហើយ ព្រមទាំងនៅក្នុងសាលាគរុកោសល្យផងដែរ។ ក្នុងនោះរួមមានសិទ្ធិដូចជា សិទ្ធិសំដែងមតិ ការពារខ្លួន ទំនួលខុសត្រូវ សមភាពជេនឌ័ ជនជាតិភាគតិច ជនពិការ និងសិទ្ធិអនីតិជន។

ជាបន្តទៀត សមាជិកមួយចំនួនក៏បានលើកឡើងផងដែរនូវសកម្មភាព ១.២.២ ទាក់ទងនិងការស្ទង់មតិលើការបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ១.៦.១ ទាក់ទងនិងការបង្កើតការិយា-ល័យការពារសិទ្ធិប្រជាពលរដ្ឋ ១.៧.១ ការបង្កើតវិទ្យាស្ថានឧក្រិដ្ឋវិទ្យា ដែលមិនទាន់បានដំណើរការនៅឡើយ។ ត្រង់ចំនុចទាំងនេះ លោក កុយ នាម ក៏បានលើកឡើងផងដែរ អោយសមាជិកអនុក្រុមការងារទាំងអស់យកចិត្តទុកដាក់ជួយទាក់ទាញដៃគូរ អភិវឌ្ឍនានារបស់ខ្លួនអោយមកចូលរួម និងគាំទ្រសកម្មភាពរបស់យើងដែលមិនទាន់បានចាប់ផ្តើមនៅឡើយនេះ ហើយដែលមានអង្គភាគ្រប់គ្រងគម្រោងជាអ្នកសម្របសម្រួល។

**(៤) ការងារផ្សេងៗ**

អង្គប្រជុំបានលើកជាសំណើដូចខាងក្រោម ៖

- អង្គភាពគ្រប់គ្រងគម្រោង គួរៀបចំគម្រោងសំណើរទាក់ទងនិងសកម្មភាព ១.២.២ ទៅ USAID, AUSAID ឬទៅអង្គការផ្សេងៗទៀតតាមដែលអាចធ្វើបានដើម្បីគាំទ្រ និងអនុវត្តគម្រោងនេះ។
- អង្គភាពគ្រប់គ្រងគម្រោង គួសរសេលិខិតទៅរដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងយុត្តិធម៌ ដើម្បីអោយមានការចាត់តាំងមនុស្សធ្វើជា Focal Point សម្រាប់ការចូល រួមនៅក្នុងអនុក្រុមការងារទី១នេះ និងទទួលខុសត្រូវនៅលើសកម្មភាព ១.៥.១ ដែលទាក់ទងនិង សុរិយោដី និងសាការី។

**(៥) កាលបរិច្ឆេទកិច្ចប្រជុំលើកក្រោយ**

អង្គប្រជុំទាំងមូលក៏បានយល់ព្រមផងដែរនូវការប្រជុំលើកក្រោយនៅថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៧ នៅវេលាម៉ោង ៩ ៖ ០០ ព្រឹក នៅសាលប្រជុំ PMU ។

អង្គប្រជុំបានបញ្ចប់ដោយបរិយាកាសរីករាយ នៅវេលាម៉ោង ១១ ៖ ០០ នៅថ្ងៃដ៏ដែល។

ធ្វើនៅថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០០៧

អ្នកធ្វើរបាយការណ៍

កូយ សៅ